សុខភាព និងជីវិត
កាន់តែប្រសើរ

# ដំណោះស្រាយផ្នែកសុខភាព

## ប្រកបដោយគុណតម្លៃសម្រាប់បុគ្គលិករបស់អ្នក



## ផលិតផលធានារ៉ាប់រងបន្ថែម AIA MedCare

គឺជាគម្រោងផលិតផលធានារ៉ាប់រងបន្ថែមលើសេវាវេជ្ជសាស្ត្រសម្រាប់បុគ្គលិករបស់ ក្រុមហ៊ុនសហគ្រាសស្ថាប័ន ឬអាជីវកម្មនានាដែលមានភាពទូលំទូលាយរួមជាមួយអត្ថប្រយោជន៍នៃការថែទាំសុខភាពជាច្រើនដូចជា ការផ្តល់សំណងលើការចំណាយដោយសម្រាកព្យាបាលនៅមន្ទីរពេទ្យរួមទាំងការវះកាត់ ការព្យាបាលដែលបណ្តាលពីជំងឺ និងដោយសារគ្រោះថ្នាក់ចៃដន្យ ការសង្គ្រោះបន្ទាន់ ក៏ដូចជា ជម្រើសអត្ថប្រយោជន៍បន្ថែមលើការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យ ការចំណាយរបស់អ្នកកំដរអ្នកជំងឺ ការថែទាំដើម្បីបង្ការជំងឺផ្សេងៗ ការថែទាំធ្មេញ ការសម្រាលកូននិងជម្រើសអត្ថប្រយោជន៍បន្ថែមជាច្រើនទៀត។ផលិតផលធានារ៉ាប់រងបន្ថែមនេះជាដំណោះស្រាយដែលមានភាពបត់បែន ដោយអ្នកអាចជ្រើសរើសកញ្ចប់ការពារបុគ្គលិកស្របតាមតម្រូវការ និងគម្រោងថវិការបស់ក្រុមហ៊ុន ឬស្ថាប័នរបស់អ្នក។



## ហេតុអ្វី ផលិតផលធានារ៉ាប់រងបន្ថែម AIA MedCare ជាជម្រើសដ៏ស័ក្តិសមបំផុត?

### លក្ខណៈពិសេសសំខាន់ៗ៖

- ផ្តល់ការការពារលើសេវាវេជ្ជសាស្រ្តដ៏ទូលំទូលាយ
- បណ្តាញដៃគូលើសេវាវេជ្ជសាស្រ្តប្រកបដោយគុណភាព
- ផ្តល់ជូននូវជម្រើសរហូតដល់ 8 គម្រោង ដែលស្របតាមតម្រូវការ និងគម្រោងថវិការបស់ក្រុមហ៊ុន ឬ ស្ថាប័នរបស់អ្នក
- ផ្តល់ជូននូវគម្រោងការពារលើសេវាវេជ្ជសាស្រ្តដ៏ល្អ ដែលអាចលើកទឹកចិត្ត បង្កើនទំនុកចិត្ត ជាពិសេសជួយថែរក្សាបុគ្គលិក ដោយធានាថាសុខភាព និងសុខុមាលភាពរបស់ពួកគេ ជាកត្តាចម្បង  ដែលត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់បំផុត។

## តើផលិតផលធានារ៉ាប់រងបន្ថែម AIA MedCare ផ្តល់អត្ថប្រយោជន៍ដល់ស្ថាប័ន និងបុគ្គលិករបស់អ្នកយ៉ាងដូចម្តេច?

| អត្ថប្រយោជន៍គោល | ជម្រើសអត្ថប្រយោជន៍បន្ថែម |
|---|---|
| • តម្លៃសេវាបន្ទប់ គ្រែ និងអាហារប្រចាំថ្ងៃ<br>• ការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ<br>• ការព្យាបាលជំងឺមហារីកដែលមិនសម្រាកក្នុងមន្ទីរពេទ្យ<br>• ការព្យាបាលដោយការលាងឈាមដែលមិនសម្រាកក្នុងមន្ទីរពេទ្យ<br>• ការព្យាបាលដោយការវះកាត់ដែលមិនសម្រាកក្នុងមន្ទីរពេទ្យ<br>• ការព្យាបាលមុន និងក្រោយពេលសម្រាកក្នុងមន្ទីរពេទ្យ សម្រាប់អ្នកជំងឺមិនសម្រាកក្នុងមន្ទីរពេទ្យ<br>• រថយន្តគិលានសង្គ្រោះបន្ទាន់<br>• ការសង្គ្រោះបន្ទាន់ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ | • ការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យ<br>• ការចំណាយរបស់អ្នកកំដរអ្នកជំងឺ<br>• ឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ<br>• ការថែទាំដើម្បីបង្ការជំងឺផ្សេងៗ<br>• ការថែទាំធ្មេញ<br>• ការថែទាំភ្នែក<br>• ការថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ<br>• ការថែទាំជំងឺផ្លូវចិត្ត<br>• ថ្លៃព្យាបាលពេលសម្រាលកូន |

## ទីតាំងភូមិសាស្ត្រនៃការធានា

**ផ្តល់ជម្រើសក្នុងការធានារ៉ាប់រងទៅលើតំបន់ចំនួន 4 ដូចជា៖ តំបន់ទី1 តំបន់ទី 2 តំបន់ទី 3 និង 4។ អ្នកអាចជ្រើសរើសគម្រោងព្យាបាលរបស់អ្នកនៅក្នុងប្រទេសណាមួយដែលបានរាយនាមនៅក្នុងតំបន់ដែលអ្នកបានជ្រើសរើស។**

| | តំបន់ទី 1 | តំបន់ទី 2 | តំបន់ទី 3 | តំបន់ទី 4 |
|---|---|---|---|---|
| សម្រាប់ការព្យាបាលទូទៅ | កម្ពុជា<br>ថៃ<br>វៀតណាម<br>មីយ៉ាន់ម៉ា<br>ឡាវ និង<br>ម៉ាឡេស៊ី | អាស៊ី | ទូទាំងពិភពលោក<br>មិនរាប់បញ្ចូល<br>សហរដ្ឋអាមេរិក | ទូទាំង<br>ពិភពលោក |
| សម្រាប់ករណីសង្គ្រោះបន្ទាន់ | ទូទាំងពិភពលោក | | | |

## តារាងអត្ថប្រយោជន៍គោល នៃផលិតផលធានារ៉ាប់រងបន្ថែម AIA MedCare

| គម្រោង | គម្រោង ទី 1 | គម្រោង ទី 2 | គម្រោង ទី 3 | គម្រោង ទី 4 | គម្រោង ទី 5 | គម្រោង ទី 6 | គម្រោង ទី 7 | គម្រោង ទី 8 |
|---|---|---|---|---|---|---|---|---|
| កម្រិតអតិបរមាប្រចាំឆ្នាំសរុប | US$10,000 | US$20,000 | US$30,000 | US$40,000 | US$50,000 | US$60,000 | US$90,000 | US$120,000 |
| កម្រិតអតិបរមាប្រចាំឆ្នាំសម្រាប់ការព្យាបាលពីជំងឺ | US$10,000 | US$20,000 | US$30,000 | US$40,000 | US$50,000 | US$60,000 | US$90,000 | US$120,000 |
| **អត្ថប្រយោជន៍លើការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ** | | | | | | | | |
| **1.តម្លៃសេវាបន្ទប់ គ្រែ និងអាហារ - ក្នុង 1ថ្ងៃ** (ការស្នាក់នៅ រួមមានអាហារ និងការថែទាំផ្នែកវេជ្ជសាស្ត្រទូទៅ) | US$25 | US$35 | US$50 | US$80 | US$120 | US$160 | US$240 | US$320 |
| **2. ការព្យាបាលជំងឺសម្រាកក្នុងមន្ទីរពេទ្យ - ក្នុង 1ឆ្នាំ៖**<br>• ថ្លៃវះកាត់ ថ្នាំសណ្តំ និងបន្ទប់វះកាត់<br>• បន្ទប់សង្គ្រោះបន្ទាន់<br>• ថ្លៃឱសថព្យាបាល ការរុំរបួស និងសម្ភារៈប្រើប្រាស់ផ្សេងៗ<br>• ថ្លៃពិនិត្យដោយគ្រូពេទ្យជំនាញ និងអ្នកឯកទេស<br>• ការបណ្តុះសរីរាង្គ ឬការប្តូរសរីរាង្គ<br>• ថ្លៃធ្វើរោគវិនិច្ឆ័យ ការពិនិត្យតាមដានជំងឺ រួមទាំង ការស្កេន MRI, CT Scan, PET Scan<br>• ការដាក់អបឆ្អឹងខ្នង ការដាក់រណបជង្គង់ ឬការដាក់ឧបករណ៍រណបដៃជើង ប្រសិនបើវាជាផ្នែកនៃដំណើរការវះកាត់ និងការព្យាបាល<br>• ការព្យាបាលដោយចលនា ដែលផ្តល់ជូនដោយគ្រូពេទ្យព្យាបាលដោយចលនាដែលមានអាជ្ញាប័ណ្ណ<br>• ការលាងឈាម<br>• ការព្យាបាលជំងឺមហារីក<br>• ការព្យាបាលដែលផ្តល់ជូនក្នុងគោលបំណងបំបាត់រោគសញ្ញា នៅពេលដែលស្ថានភាព ជំងឺរបស់លោកអ្នក ត្រូវបានវិនិច្ឆ័យថាដល់ដំណាក់កាលចុងក្រោយ<br>• ថ្លៃឱសថព្យាបាលនៅផ្ទះដែលមិនលើសពី 7 ថ្ងៃ បន្ទាប់ពីចេញពីមន្ទីរពេទ្យ | US$10,000 | US$20,000 | US$30,000 | US$40,000 | US$50,000 | US$60,000 | US$90,000 | US$120,000 |

| អត្ថប្រយោជន៍ការព្យាបាលមិនសម្រាកក្នុងមន្ទីរពេទ្យ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **3. ការព្យាបាលអ្នកជំងឺមហារីកដែលមិនសម្រាកក្នុងមន្ទីរពេទ្យ - ក្នុង 1ឆ្នាំ** (រួមបញ្ចូលការព្យាបាលដោយវិទ្យុសកម្ម និងការព្យាបាលដោយចាក់សារធាតុគីមី) | US$10,000 | US$20,000 | US$30,000 | US$40,000 | US$50,000 | US$60,000 | US$90,000 | US$120,000 |
| **4. ការព្យាបាលដោយការលាងឈាមដែលមិនសម្រាកក្នុងមន្ទីរពេទ្យ - ក្នុង 1ឆ្នាំ** (រួមបញ្ចូលលើការលាងឈាម និងការពិគ្រោះយោបល់) | US$10,000 | US$20,000 | US$30,000 | US$40,000 | US$50,000 | US$60,000 | US$90,000 | US$120,000 |
| **5. ការព្យាបាលដោយការវះកាត់ដែលមិនសម្រាកក្នុងមន្ទីរពេទ្យ - ក្នុង 1ឆ្នាំ** (រួមបញ្ចូលថ្លៃចំណាយមុននិងក្រោយការពិគ្រោះយោបល់ និងដំណើរការនៃការវះកាត់) | US$10,000 | US$20,000 | US$30,000 | US$40,000 | US$50,000 | US$60,000 | US$90,000 | US$120,000 |
| **6. ការព្យាបាលមុន និងក្រោយពេលសម្រាកក្នុងមន្ទីរពេទ្យ - សម្រាប់ការសម្រាកព្យាបាលក្នុង 1ដង** (មានសុពលភាពក្នុងរយៈពេល 90 ថ្ងៃមុន និងក្រោយពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ)<br>• ការពិគ្រោះជាមួយវេជ្ជបណ្ឌិតឯកទេស<br>• ការធ្វើតេស្តរោគវិនិច្ឆ័យ និងការតាមដាន<br>• ថ្នាំ និងការព្យាបាលតាមវេជ្ជបញ្ជា (រាប់បញ្ចូលទាំងការព្យាបាលដោយចលនា ការព្យាបាលឆ្អឹង និងការព្យាបាលដោយប្រើ Chiropractic) | US$50 | US$200 | US$400 | US$600 | US$700 | US$800 | US$1,000 | US$1,200 |
| **7. រថយន្តគិលានសង្គ្រោះបន្ទាន់ - សម្រាប់ការសម្រាកព្យាបាលក្នុង 1ដង** | US$300 | US$400 | US$450 | US$500 | US$550 | US$600 | US$700 | US$800 |
| **8. អត្ថប្រយោជន៍លើការសង្គ្រោះបន្ទាន់ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ - សម្រាប់ការចូលសម្រាកព្យាបាលក្នុង 1ដង** | US$100 | US$300 | US$400 | US$600 | US$700 | US$800 | US$1,000 | US$1,200 |
| **9. អត្ថប្រយោជន៍លើសំណងបន្ទាប់បន្សំ** (ថ្លៃបន្ទប់ គ្រែ និងអាហារប្រចាំថ្ងៃ ឬការព្យាបាលអ្នកជំងឺមហារីកដែលមិនសម្រាកក្នុងមន្ទីរពេទ្យ ដែលត្រូវបានទូទាត់សងដោយគម្រោងធានារ៉ាប់រងផ្សេង រហូតដល់ចំនួន15 ថ្ងៃក្នុង 1ឆ្នាំ) | US$15 | US$20 | US$35 | US$60 | US$70 | US$80 | US$90 | US$100 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទឹកប្រាក់កំណត់អតិបរមាសម្រាប់ការទូទាត់ជាមួយបណ្តាញមន្ទីរពេទ្យដៃគូ | US$75 | US$200 | US$400 | US$600 | US$700 | US$800 | US$1,000 | US$1,200 |

## តារាងអត្ថប្រយោជន៍នៃជម្រើសអត្ថប្រយោជន៍បន្ថែម ៖

| គម្រោង | គម្រោង ទី 1 | គម្រោង ទី 2 | គម្រោង ទី 3 | គម្រោង ទី 4 | គម្រោង ទី 5 | គម្រោង ទី 6 | គម្រោង ទី 7 | គម្រោង ទី 8 |
|---|---|---|---|---|---|---|---|---|
| ជម្រើសអត្ថប្រយោជន៍បន្ថែម | | | | | | | | |
| 1. ចំណាយរបស់អ្នកកំដរអ្នកជំងឺ - ក្នុង 1ឆ្នាំ | US$10,000 | US$20,000 | US$30,000 | US$40,000 | US$50,000 | US$60,000 | US$90,000 | US$120,000 |
| 2. ឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ - ក្នុង 1ឆ្នាំ | US$250 | US$500 | US$750 | US$1,000 | US$1,100 | US$1,200 | US$1,300 | US$1,500 |
| 3. ការថែទាំដើម្បីបង្ការជំងឺផ្សេងៗ - ក្នុង 1ឆ្នាំ (ការពិគ្រោះយោបល់ ការតាមដានជំងឺ និងការចាក់ថ្នាំបង្ការជំងឺផ្សេងៗ) | US$30 | US$60 | US$75 | US$90 | US$120 | US$150 | US$180 | US$240 |
| 4. ការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យ - ក្នុង 1ឆ្នាំ/- ក្នុង 1ដង (ការពិគ្រោះយោបល់ ថ្នាំតាមវេជ្ជបញ្ជា សម្ភារៈរុំរបួស និងការតាមដានក្រោយចេញពីពេទ្យ) | US$300 /US$30 | US$600 /US$40 | US$750 /US$50 | US$900 /US$60 | US$1,200 /US$80 | US$1,500 /US$100 | US$1,800 / US$120 | US$2,400 /US$160 |
| 5. ការថែទាំធ្មេញ* - ក្នុង 1ឆ្នាំ | US$150 | US$300 | US$400 | US$500 | US$600 | US$700 | US$800 | US$1,000 |
| 6. ការថែទាំភ្នែក* - ក្នុង 1ឆ្នាំ | US$50 | US$100 | US$150 | US$200 | US$225 | US$250 | US$275 | US$300 |
| 7. ការថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ- ក្នុង 1ឆ្នាំ | - | - | - | - | - | US$10,000 | US$10,000 | US$10,000 |
| 8. ការថែទាំជំងឺផ្លូវចិត្ត - ក្នុង 1ឆ្នាំ | - | - | US$3,000 | US$3,000 | US$3,000 | US$5,000 | US$5,000 | US$5,000 |
| 9. ថ្លៃព្យាបាលពេលសម្រាលកូន - ក្នុង 1ឆ្នាំ | US$120 | US$450 | US$850 | US$1,250 | US$1,800 | US$2,500 | US$3,200 | US$3,800 |

**អត្ថប្រយោជន៍ខាងលើនេះអាចទទួលបានក្នុងករណីជម្រើសអត្ថប្រយោជន៍បន្ថែមលើការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យត្រូវបានជ្រើសរើសតែប៉ុណ្ណោះ។*

***សម្គាល់៖*** *តារាងអត្ថប្រយោជន៍ខាងលើគឺជាគម្រោងរៀបចំជាកញ្ចប់រៀបចំឡើងសម្រាប់ផ្តល់ភាពងាយស្រួលក្នុងការជ្រើសរើសហើយក្រុមហ៊ុនក៏អាចមានភាពបត់បែនក្នុងការផ្តល់គម្រោងធានារ៉ាប់រង តាមការស្នើសុំ តម្រូវការ និងកញ្ចប់ថវិការរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង។*

## ការទាមទារសំណង

ប្រសិនបើអ្នក ចង់ធ្វើការទាមទារសំណង អ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាង ក្នុងកំឡុងពេល 90ថ្ងៃ ពីការកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ អ្នកអាចទាញយកទម្រង់បែបបទទាមទារសំណង ពីគេហទំព័ររបស់យើង គឺ aia.com.kh ឬ ពីទីប្រឹក្សាផែនការជីវិត AIA។

រាល់ឯកសារ និងភស្តុតាងចាំបាច់ដែលត្រូវដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន AIA មានដូចជា វិក័យប័ត្រច្បាប់ដើម វិញ្ញាបនបត្រវេជ្ជសាស្ត្រ របាយការណ៍ចេញពីមន្ទីរពេទ្យ និងឯកសារវេជ្ជសាស្ត្រផ្សេងទៀត។ រាល់ឯកសារវេជ្ជសាស្ត្រទាំងអស់ ត្រូវតែទទួលស្គាល់ពីមន្ទីរវេជ្ជសាស្ត្រដែលមានអាជ្ញាបណ្ណស្របច្បាប់លើសេវាព្យាបាលវេជ្ជសាស្ត្រនៅក្នុងប្រទេស។

អ្នកទាមទារសំណងអាចស្នើសុំសំណង ប្រសិនបើការព្យាបាលជំងឺ កើតឡើងក្នុងកំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

## ការទទួលយកសំណើធានារ៉ាប់រង

ដើម្បីស្វែងយល់កាន់តែច្បាស់ពីផលិតផលធានារ៉ាប់រងបន្ថែម AIA MedCare ក្នុងការផ្តល់ការការពារជូនបុគ្គលិករបស់អ្នក សូមទាក់ទងទីប្រឹក្សាផែនការជីវិត AIA ឬ សេវាបម្រើអតិថិជន AIA Client Care តាមរយៈទូរស័ព្ទលេខ (855) 86 999 242/(855) 23 999 242 ឬ អ៊ីមែលមកកាន់ KH.Care@aia.com ឬ ចូលទៅកាន់គេហទំព័រ aia.com.kh។

# ករណីមិនធានា

### ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាលើ៖

1. ការវះកាត់ និងការព្យាបាលកែសម្ផស្ស ឬការព្យាបាលដើម្បីកែលម្អរូបរាង ការព្យាបាលដើម្បីជម្រុះរោម ឬសក់ ឬបណ្តុះសក់ ការផ្លាស់ប្តូរពណ៌ស្បែក ឬពណ៌ភ្នែក លើកលែងការវះកាត់កែសម្រួលមុខងារប្រើប្រាស់បន្ទាប់ពីទទួលរងគ្រោះថ្នាក់ចៃដន្យ ឬការព្យាបាលដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ឬ
2. ការព្យាបាលដែលចាំបាច់ដែលបណ្តាលមកពីផលប៉ះពាល់នៃផ្នែកវិទ្យុសកម្ម ជីវសាស្ត្រ ឬសារធាតុគីមី ដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រង អាចចូលរួមក្នុងទំនាស់ សង្គ្រាម សកម្មភាពរបស់សត្រូវបរទេស ការឈ្លានពាន សង្គ្រាមស៊ីវិល បាតុកម្ម ការបះបោរ កុបកម្ម បដិវត្តន៍ ការផ្តួលរលំរដ្ឋាភិបាលស្របច្បាប់ ការផ្ទុះអាវុធនៃសង្គ្រាម ឬព្រឹត្តិការណ៍ណាមួយដែលប្រហាក់ប្រហែលនឹងព្រឹត្តិការណ៍ដែលបានរៀបរាប់នេះ។ទាំងនេះរាប់បញ្ចូលទាំងការព្យាបាលទាំងឡាយដែលបណ្តាលមកពីការប្រឈមខ្លួនទៅនឹងហានិភ័យរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដូចជា ការទៅកាន់កន្លែងដែលមានចលាចលសង្គមមិនថាក្នុងនាមជាអ្នកឃ្លាំមើលឬអ្នកទស្សនាក៏ដោយ។សូមបញ្ជាក់ផងដែរថាការធានានឹងផ្តល់ជូនសម្រាប់ការព្យាបាលចាំបាច់ដែលបណ្តាលមកពីសកម្មភាពភេរវកម្ម ក្នុងករណីដែលសកម្មភាពនេះ មិនបានបណ្តាលមកពីផលប៉ះពាល់ផ្នែកវិទ្យុសកម្ម ជីវសាស្ត្រ ឬសារធាតុគីមី
3. ការព្យាបាលដែលបណ្តាលមកពីការចូលរួមនៅក្នុងសកម្មភាពកងទ័ព ឬសកម្មភាពកីឡាជាអាជីព ឬ
4. ការប្រើប្រាស់ឱសថដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាពឬឱសថដែលស្ថិតនៅក្នុងកំឡុងពេលការធ្វើពិសោធន៍នៅឡើយ។ នេះមានន័យថា ឱសថទាំងនោះត្រូវទទួលបានអាជ្ញាប័ណ្ណដោយភ្នាក់ងារឱសថ អឺរ៉ុប (the European Medicines Agency) ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅក្នុងសហភាពអឺរ៉ុបឬពីរដ្ឋបាលផ្នែកឱសថ និងចំណីអាហារនៃសហរដ្ឋអាមេរិក (the US Food and Drug Administration (FDA) ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលការព្យាបាលនៅកន្លែងផ្សេងទៀតនៅក្នុងសកលលោក ហើយឱសថនោះត្រូវបានប្រើប្រាស់ក្នុងលក្ខខណ្ឌនៃអាជ្ញាប័ណ្ណនោះតែប៉ុណ្ណោះ ឬ
5. ការព្យាបាលដែលមិនមានការទទួលស្គាល់ថាមានប្រសិទ្ធភាពឬការព្យាបាលដែលស្ថិតនៅក្នុងកំឡុងពេលការធ្វើពិសោធន៍នៅឡើយ។ សម្រាប់ការព្យាបាលដែលមានការទទួលស្គាល់ នេះមានន័យថា ជាវិធីសាស្ត្រ និងការអនុវត្តនានា ដែលបានឆ្លងកាត់ការសាកល្បង និងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រយ៉ាងត្រឹមត្រូវ និងត្រូវបានផ្តល់ភស្តុតាងយ៉ាងគ្រប់គ្រាន់នៅក្នុងសៀវភៅវេជ្ជសាស្ត្រដែលបានបោះផ្សាយសម្រាប់គោលដៅជាក់លាក់មួយដើម្បីចាត់ទុកថាជាការបង្ហាញពីការព្យាបាលយ៉ាងមានសុវត្ថិភាព និងប្រសិទ្ធភាព ឬ
6. ការព្យាបាលឲ្យមានកូន ការពន្យារកំណើត ឬការបង្អាក់កំណើត ឬគ្រាវ ឬការព្យាបាលក្នុងការពន្យារកំណើត ការកែភេទ អសមត្ថភាពផ្លូវភេទ ឬ
7. ការព្យាបាលដោយបុគ្គលដែលមិនមែនជាគ្រូពេទ្យ ឬគ្រូពេទ្យដែលមិនមានអាជ្ញាប័ណ្ណវិជ្ជាជីវៈត្រឹមត្រូវ ឬ
8. ការវះកាត់ព្យាបាលគភ៌ ឬទារកនៅក្នុងផ្ទៃ ឬ
9. ចំណាយសេវាវេជ្ជសាស្ត្រដែលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹងមេរោគអេដស៍ (HIV) និង/ឬ ជំងឺដែលពាក់ព័ន្ធនឹងមេរោគអេដស៍ (HIV) ដោយរាប់បញ្ចូលទាំងជំងឺអេដស៍ ឬរោគសញ្ញារបស់ជំងឺអេដស៍ និង/ឬ រោគសញ្ញានានាដែលបំប្លែងពីរោគសញ្ញានៃជំងឺអេដស៍នេះ ដែលកើតឡើងក្នុងកំឡុងពេលមួយឆ្នាំដំបូង រាប់ចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រងឬ
10. ចំណាយដែលមិនមែនសម្រាប់ការព្យាបាលជំងឺ ដូចជា ថ្លៃសេវាទូរស័ព្ទ ការជួលទូរទស្សន៍ សារព័ត៌មាន ផលិតផលផ្តល់សំណើមស្បែក គ្រីម គ្រឿងប្រដាប់សម្រាប់ងូតទឹក អាហារបំប៉ន និងវីតាមីន ថ្នាំដុសធ្មេញ ឬសាប៊ូ ឬ
11. ចំណាយដែលមិនប្រក្រតី មិនសមហេតុផល ក្នុងតំបន់ដែលទទួលការព្យាបាល ឬ
12. ការព្យាបាលប្រឆាំងនឹងភាពធាត់ រួមមានដោយមិនកំណត់ត្រឹម ការចង ឬការវះកាត់ទាក់ទងនឹងក្រពះ ការយកចេញនូវកោសិកា និងខ្លាញ់ដែលលើស ឬ
13. ការព្យាបាលដែលមិនមានភាពចាំបាច់ក្នុងការព្យាបាល ឬ

14. ការព្យាបាលដែលជាធម្មតាមិនសម្រាកនៅក្នុងមន្ទីរពេទ្យដោយរួមបញ្ចូលទាំងឱសថ និងការរុំរបួស ការប្រឹក្សាយោបល់និងការពិនិត្យតាមដានជំងឺ ឬក៏រួមទាំងការពិនិត្យកំឡុងពេល និងក្រោយពេលមានផ្ទៃពោះ លើកលែងតែការព្យាបាលដែលមិនសម្រាកនៅក្នុងមន្ទីរពេទ្យដែលត្រូវបានអនុញ្ញាតហើយមានបង្ហាញនៅលើតារាងអត្ថប្រយោជន៍ យ៉ាងណាក៏ដោយប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យ ក្រុមហ៊ុននឹងបង់ជូននូវអត្ថប្រយោជន៍ដែលរាប់បញ្ចូលទាំងឱសថ ការរុំរបួស ការប្រឹក្សាយោបល់ និងការពិនិត្យតាមដានជំងឺរហូតដល់កម្រិតអតិបរមាដែលបានកំណត់ក្រោមជម្រើសអត្ថប្រយោជន៍លើការព្យាបាលដែលមិនសម្រាកក្នុងមន្ទីរពេទ្យ ឬ
15. ការពិនិត្យសុខភាពដើម្បីបង្ការជំងឺផ្សេងៗ ការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការ ការធ្វើរោគវិនិច្ឆ័យ និងការពិនិត្យតាមដានជំងឺក្នុងដំណាក់កាលដំបូងនៃជំងឺដែលគ្មានរោគសញ្ញា យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺផ្សេងៗក្រុមហ៊ុននឹងបង់ជូនការពិនិត្យសុខភាពដើម្បីបង្ការជំងឺផ្សេងៗនោះ រហូតដល់កម្រិតអតិបរមាដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំដើម្បីបង្ការជំងឺផ្សេងៗ ឬ
16. ការចាក់ថ្នាំបង្ការ ក្រៅពីការចាក់ថ្នាំបង្ការដំបូងសម្រាប់ទារកទើបនឹងកើត ដែលត្រូវបានធានានៅក្រោមអត្ថប្រយោជន៍ពេលសម្រាលកូន ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន ឬ
17. ការព្យាបាលជំងឺផ្លូវចិត្ត ទោះបីជាតម្រូវឲ្យចូលសម្រាកក្នុងមន្ទីរពេទ្យក៏ដោយ ដោយឡែក ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំជំងឺផ្លូវចិត្តក្រុមហ៊ុននឹងបង់ជូនចំណាយលើការថែទាំជំងឺផ្លូវចិត្ត រហូតដល់កម្រិតដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំជំងឺផ្លូវចិត្ត ឬ
18. ការថែរក្សាសុខភាពមាត់ធ្មេញ និងអញ្ចាញ (ឬប្រហាក់ប្រហែល) យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំធ្មេញក្រុមហ៊ុននឹងបង់ជូនចំណាយលើសុខភាពមាត់ធ្មេញនិងអញ្ចាញ រហូតដល់កម្រិតដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំធ្មេញ ឬ
19. ការព្យាបាលភ្នែក ឬចក្ខុវិញ្ញាណ យ៉ាងណាក៏ដោយ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើការថែទាំភ្នែក ក្រុមហ៊ុននឹងបង់ជូនចំណាយលើការថែទាំភ្នែក រហូតដល់កម្រិតដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើការថែទាំភ្នែក ឬ
20. ចំណាយសេវាវេជ្ជសាស្ត្រ ដែលកើតឡើងក្នុងរយៈពេលនៃការរងចាំ លើកលែងតែចំណាយសេវាវេជ្ជសាស្ត្រដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ ដែលកើតឡើងក្នុងរយៈពេលនៃការរងចាំ ដោយអនុលោមទៅតាមករណីលើកលែងដទៃទៀត ឬ
21. ការជំនួសសរីរាង្គខាងក្រៅ (ឧបករណ៍សិប្បនិម្មិត) និងឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ និងឧបករណ៍ពាក់ព័ន្ធនានា ក្រៅពីឧបករណ៍ទាំងឡាយណាដែលជាផ្នែកនៃការវះកាត់ ឬរួមបញ្ចូលក្នុងការព្យាបាល យ៉ាងណាក៏ដោយប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបានជ្រើសរើសយកជម្រើសអត្ថប្រយោជន៍លើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ ក្រុមហ៊ុននឹងបង់ជូនចំណាយលើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺរហូតដល់កម្រិតអតិបរមាដែលបានកំណត់នៅលើតារាងអត្ថប្រយោជន៍ ក្រោមជម្រើសអត្ថប្រយោជន៍លើឧបករណ៍ប្រើប្រាស់សម្រាប់ព្យាបាលជំងឺ ឬ
22. ចំណាយលើការទទួលសរីរាង្គ ឬជាលិកាពីការបរិច្ចាក ឬចំណាយរដ្ឋបាលដែលពាក់ព័ន្ធណាមួយ (ដូចជា ចំណាយលើការស្វែងរកការបរិច្ចាគ) ឬ
23. ចំណាយបន្ថែមសម្រាប់ការទទួលបានរបាយការណ៍ពេទ្យ ឬការដាក់ពាក្យស្នើសុំទាមទារសំណង ឬចំណាយរដ្ឋបាលផ្សេង ៗ ទៀត ឬ
24. ការព្យាបាលការញៀន (ដូចជា ការញៀនគ្រឿងស្រវឹង សារជាតុ ឬថ្នាំញៀន) ឬការប្រើប្រាស់សារជាតុញៀននានាលើសចំណុះ (ដូចជា ការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការប្រើប្រាស់សារជាតុ ឬថ្នាំញៀនលើសចំណុះ) ឬតម្រូវការព្យាបាលព្យាបាលជំងឺ ឬរបួសនានា ដែលបង្កឡើងពីការការប្រើប្រាស់គ្រឿងស្រវឹងលើសចំណុះ ឬការញៀន មិនថាដោយផ្ទាល់ ឬដោយប្រយោលឡើយ។

**ការិយាល័យកណ្ដាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គុំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA